**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការផ្តល់

## សម្បទានដីសេដ្ឋកិច្ច

## ជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## នៅខេត្តស្ទឹងត្រែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ១៩៩៦ដែល ប្រកាសឱ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង

របស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការ ធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នៃដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ មានទំហំចំនួន ២០.០០០ ម៉ែត្រការ៉េ (ពីម៉ឺនម៉ែត្រការ៉េ) ដែលស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តស្ទឹងត្រែង។ ទីតាំងបួងដីត្រូវបានកំណត់ក្នុងផែនទីគោល ដូចមានជូនភ្ជាប់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយមានចំណុចនិយាមកា ដូចខាងក្រោម ÷

A ( X : ០៦១១៩៥៧ Y : ១៥៣៨៧៥៣ )
B ( X : ០៦១២០៤៥ Y : ១៥៣៨៧០៦ )
C ( X : ០៦១១៨៤៧ Y : ១៥៣៨៦៧៥ )
D ( X : ០៦១១៧៥៩ Y : ១៥៣៨៧២១ )

**មាត្រា ២.-**

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

**មាត្រា ៣.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ២០.០០០ ម៉ែត្រការ៉េ (ពីម៉ឺនម៉ែត្រការ៉េ) ដូចមានចែងក្នុងមាត្រាខាងលើ នៃអនុក្រឹត្យនេះ ដែលជាសម្បត្តិសាធារណរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៤.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ផ្តល់ជា សម្បទានដីសេដ្ឋកិច្ច ជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមគោលការណ៍ និងបទដ្ឋានកំណត់ របស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ